នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០៤/០២/០៧-០៩-២០០៩-អវតក/កសចស(អបជ៥៨)
**ដាក់ទៅ** : អង្គបុរេជំនុំជម្រះ
**ថ្ងៃដាក់** : ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញាអន្តរជាតិ
**ភាសាដើម** : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 27-Aug-2018, 11:43
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** សម្ងាត់

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គបុរេជំនុំជម្រះ:** សម្ងាត់/Confidential

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំចំនួនពីររបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងនឹងបណ្ដឹងឧទ្ធរណ៍របស់ពួកគេ ជំទាស់នឹងដីកាសម្រេចលើភាពអាចទទួលយកបានរបស់ សចសអ

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញាអន្តរជាតិ**
លោក Nicholas KOUMJIAN

**ចម្លងជូន:**
**សហព្រះរាជអាជ្ញាជាតិ**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jim BAIK
ចៅក្រម ហួត វុទ្ធី

**មេធាវីតំណាងដើមបណ្ដឹង**
**រដ្ឋប្បវេណីទាំងអស់នៃសំណុំរឿង០០៤/២**

**សហមេធាវី អោ អាន:**
មុំ លុជ្ស
Richard ROGERS
Göran SLUITER

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("សចសអ") បានចេញដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ ("ដីកាសម្រេចលើភាពអាចទទួលយកបាន")[1]។

2. នៅក្នុងសំណើសុំ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបួននាក់ បានស្នើសុំបន្ថែមចំនួនទំព័រ និងបន្ថែមរយៈពេលសម្រាប់ប្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចលើភាពអាចទទួលយកបាន និងសុំការអនុញ្ញាតដាក់បណ្ដឹងឧទ្ធរណ៍របស់ខ្លួនតែមួយភាសា ដោយដាក់សំណៅបកប្រែតាមក្រោយ ("សំណើសុំទីមួយ")[2]។

3. នៅក្នុងសារណាដែលបានដាក់នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីចំនួនប្រាំមួយរូប បានចូលរួមគាំទ្រទៅនឹងសំណើសុំទីមួយ និងស្នើសុំពន្យាពេលយូរជាងមុនសម្រាប់ប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើភាពអាចទទួលយកបាន ("សំណើសុំទីពីរ")[3]។

## II. សំណើ

4. សហព្រះរាជអាជ្ញាអន្តរជាតិមិនជំទាស់ទៅនឹងសំណើសុំទាំងពីរនេះទេ ដោយយោងទៅលើភាពស្មុគស្មាញនៃអង្គហេតុ និងដីកាដំណោះស្រាយដ៏ច្រើនទំព័ររបស់ សចសអ (ជាង៤០០ ទំព័រ) និងដោយហេតុថាការបកប្រែដីកាដំណោះស្រាយនេះបច្ចុប្បន្ននេះកំពុងតែតំណើរការនៅឡើយ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

[1] ឯកសារ **D362** ដីកា**សម្រេច**លើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨។

[2] ឯកសារ **D362/1** សំណើជាបន្ទាន់របស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ស្នើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ ក្នុងការដាក់បណ្ដឹងឧទ្ធរណ៍ជំទាស់ទៅនឹង សេចក្ដីសម្រេចពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨។ សំណើនេះបានដាក់ជាភាសាអង់គ្លេសនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ និងបានជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨។

[3] ឯកសារ **D362/2** សារណាចូលរួម និងផ្ដល់ការគាំទ្របន្ថែមទៅលើ "សំណើបន្ទាន់របស់សហមេធាវីតំណាងដើម បណ្ដឹងរដ្ឋប្បវេណីសុំពន្យារពេល និងបន្ថែមចំនួនទំព័រ ក្នុងការដាក់បណ្ដឹងឧទ្ធរណ៍ជំទាស់នឹង សេចក្ដីសម្រេចពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២" ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨។ សំណើនេះបានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ និងជាភាសាខ្មែរនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨។